# ព្រះរាជពិធីច្រត់ព្រះនង្គ័ល

ច្រត់ព្រះនង្គ័ល ជាព្រះរាជប្រវេណីមួយរបស់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ហើយជាទំនៀមដែលបន្តតាំងពីបុរាណកាលមក។ ដោយឡែកប្រវេណីនេះ មិនទាក់ទងនឹងរបរចិញ្ចឹមជីវិតរបស់ព្រះមហាក្សត្រនោះទេ ប៉ុន្តែព្រះអង្គជាម្ចាស់ដីក្នុងព្រះរាជាណាចក្រនេះ ដែលមានតួនាទីក្នុងការចាប់ផ្តើម ឬអនុញ្ញាតិបើកឱ្យចាប់ផ្តើមបង្កបង្កើនផលជារៀងរាល់ឆ្នាំ។ ម្យ៉ាងទៀត កិច្ចពិធីនេះ គឺជាមង្គលដល់ការធ្វើស្រែរបស់រាស្ត្រ ដ្បិតព្រះមហាក្សត្រជាអ្នកមានបុណ្យបារមីធំ ដូច្នេះពិធីដែលរៀបចំដោយព្រះអង្គ នឹងធ្វើឱ្យរញ្ជួយដល់ទេពនិករទាំងឡាយ មានព្រះឥន្ទ្រ និងវស្សវលាហកទេវបុត្រដែលជាទេពខាងភ្លៀងឱ្យបង្អុរទឹកភ្លៀងស្រោចស្រពផែនពសុធា និងធ្វើឱ្យធញ្ញជាតិទាំងឡាយទទួលបានផលជាបរិបូណ៌ (រូបលេខ១)។[១]

ជាទូទៅមុនថ្ងៃច្រត់ព្រះនង្គ័ល៣ថ្ងៃ គឺត្រូវនឹងថ្ងៃ១រោច ២រោច ៣រោច ខែវិសាខ ក្រុមបារគូនៃព្រះបរមរាជវាំង នឹងរៀបចំធ្វើហោមពិធីបូជាដល់ទេវតា ក្នុងរោងពិធីចំនួន៩ នៅតាមទិស ក្នុងវាលព្រះស្រែ។ ហើយរហូតដល់ថ្ងៃទី៤រោច ខែវិសាខ ទើបនឹងហែហមមន្ត្រីច្រត់ព្រះនង្គ័ល ដែលតំណាងឱ្យព្រះមហាក្សត្រចេញពីព្រះបរមរាជវាំងទៅកាន់វាលព្រះស្រែ។[២] ក្នុងនោះគោចំនួន៣នឹម ដែលគេទឹមសម្រាប់ច្រត់ព្រះនង្គ័ល ហៅថាព្រះគោ ឬឧសភរាជ។ ការច្រត់ព្រះនង្គ័លផ្តើមឡើងនៅវេលាព្រឹកម៉ោង៧កន្ទះ ហើយចេញដំណើរពីទិសនិរតី ក្នុងទិសដៅប្រទក្សិណ (វិលស្តាំ) ចំនួន៣ជុំ។ នៅពីក្រោយមន្ត្រីដែលតំណាងព្រះមហាក្សត្រច្រត់ព្រះនង្គ័លនោះ មានស្ត្រីម្នាក់ដើរតាមពីក្រោយព្រួសស្រូវ និងធញ្ញជាតិទៅក្នុងគន្លងដែលបានភ្ជួររត្រឡប់នោះ ដែលគេហៅថា “**ព្រះមេហួរ**”។ បន្ទាប់ពីបានច្រត់ព្រះនង្គ័លចំនួន៣ជុំរួចហើយ ទើបគេលែងគោឧសភរាជឱ្យបរិភោគអាហារផ្សេង៧យ៉ាងដែលគេបានរៀបចំ ជាអាទិ៍មាន ស្រូវ ពោត សណ្តែក ល្ង ស្មៅ ទឹក និងស្រា។ ដោយឡែកចំពោះលទ្ធផលនៃការផ្សងនេះ និងបកស្រាយដោយអាចារ្យនៃព្រះបរមរាជវាំង ឬហៅថាក្រុមបារគូទៅដល់ព្រះមហាក្សត្រ មន្ត្រី និងប្រជារាស្ត្របានជ្រាប (រូបលេខ២)។

តាមទំនៀមដើម បានបញ្ជាក់យ៉ាងច្បាស់ក្នុងច្បាប់ក្រមពលទេព ដោយរៀបរាប់ថា បើកដល់ថ្ងៃ៣រោច ខែវិសាខកាលណា មានសំបុត្រប្រកាសមួយពីព្រះបរមរាជវាំង និង

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

---

[១] ពុទ្ធសាសនបណ្ឌិត្យ, ១៩៥១: ៨៦

[២] Ibit, ១៩៥១: ៨១

អត្ថបទដោយ៖ មាស សុភាព

មានវាយគង វាយឃ្មោះផ្ដល់ដំណឹងដល់អស់ប្រជាកសិករឱ្យចាប់ផ្ដើមបោះនង្គ័ល រនាស់ធ្វើសម្រះ ចងគោ ក្របី សេះ រកទីវាលដើម្បីឃ្វាលថែរក្សា ហើយបើស្រែណាល្មមព្រួស បុក ដាំ ក៏ឱ្យចាប់ផ្ដើមធ្វើ បើស្រែណាល្មមសាបក៏ឱ្យសាបព្រួស។

ដូចដែលបានបញ្ជាក់ពីខាងដើម ពីធីច្រត់ព្រះនង្គ័លជាទំនៀមចាស់របស់ព្រះរាជាណាចក្រកម្ពុជា ក៏ប៉ុន្តែមានប្រទេសជាច្រើនផ្សេងទៀតក្នុងសកលលោកនេះដែលមានទំនៀមច្រត់ព្រះនង្គ័លផងដែរ តួយ៉ាងដូចជាក្នុងសង្គមអឺរ៉ុប ដែលផ្ដើមចេញពីពួកក្រិចមានលេចឡើងក្នុងសង្គមអេហ្ស៊ីប ចិន ថៃ ភូមា និងជាពិសេសនៅក្នុងសង្គមឥណ្ឌា (រូបភាពទី៣)។[៣]

ទំនៀមទាក់ទងនឹងការភ្ជួររាស់នេះដំបូងឡើយ គឺគេជឿថាមនុស្សអាចនឹងកែប្រែធម្មជាតិ តាមរយៈកិច្ចបូជាចំពោះព្រះ[៤] ដើម្បីធ្វើឱ្យផលដំណាំទទួលបានទិន្នផលល្អ[៥]។ ម្យ៉ាងទៀតការភ្ជួររាស់ដីជាមធ្យោបាយធ្វើឱ្យមានភាពបរិសុទ្ធ និងជាការប្រកាសទទួលយកកម្មសិទ្ធក្នុងការប្រើប្រាស់ដី ឬសម្រាប់គោលបំណងនៃការស្ថាបនា ឬដើម្បីបង្កបង្កើនផល។[៦] ក្រៅពីនេះ នង្គ័ល ជានិមិត្តរូបដ៏មានឥទ្ធិពលសម្រាប់បង្ហាញលើអំណាចធម្មជាតិ និងសម្រាប់ផ្ដល់សញ្ញាដល់សង្គមថាបានចាកចេញពីសង្គមបរបាញ់ និងប្រមូលផល។ គេជឿថានង្គ័ល ជានិមិត្តរូបនៃអង្គជាតិបុរស ដែលបានជ្រាបចូល និងបង្កកំណើតផលតាមរយៈព្រះនាងធរណី។ ចំណុចនេះ ពួកអឺរ៉ុបគេមានឯកសារនិយាយពីអាពាហ៍ពិពាហ៍របស់ព្រះស្ថានសួគ៌ (មេឃ)និងព្រះនាងធរណីផងដែរ។[៧]

ការភ្ជួររាស់ គឺធ្វើឡើងដោយម្ចាស់ដី (ក្នុងន័យរបស់ខ្មែរ គឺព្រះមហាក្សត្រ) ដែលជាតំណាងព្រះព្រហ្មព្រះអាទិករ។ គោ ត្រូវបានគេចាត់ទុកថាជាព្រះអាទិត្យ និងព្រះច័ន្ទ ហើយខណៈដែលនង្គ័លជានិមិត្តរូបព្រះ **វារាហ** (ព្រះវិស្ណុ ក្នុងទម្រង់ជាជ្រូកព្រៃ)។ អត្ថន័យនៃការភ្ជួររាស់ត្រង់ចំណុចនេះបញ្ជាក់ថាម្ចាស់ដី បានកាន់កាប់តំបន់នោះ និងធ្វើឱ្យទីនោះបានផល។[៨]

---

[៣] Armstrong, 1943: 4.

[៤] Sahasrabudhe and Kashyap, 2016: 4.

[៥] Armstrong, 1943: 4

[៦] Sahasrabudhe and Kashyap, 2016: 157.

[៧] Armstrong, 1094: 255.

[៨] Sahasrabudhe and Kashyap, 2016: 158.

ជំនឿអំពីការកែប្រែដីឱ្យបានជាបរិសុទ្ធ ក៏មានបង្ហាញក្នុងគម្ពីរព្រះពុទ្ធសាសនា នៅស្រីលង្កា **មហាវាមស** ក្នុងរវាងសតវត្សទី៣-៤មុនគ្រិស្តសករាជ។[៩] ព្រឹត្តិការណ៍នេះ កើតឡើងនៅចុងបញ្ចប់នៃការប្រកាសបង្កើតពុទ្ធសាសនា។ នៅក្នុងពេលប្រារព្ធពិធីនោះ ព្រះមហាក្សត្របានប្រើនង្គ័លមាសទាញដោយដំរីរបស់រដ្ឋ និងភ្ជួរកាត់ដីទីក្រុង កែប្រែឱ្យមានការសាងសង់លំនៅដ្ឋាន រួមទាំងវត្តអារាមព្រះពុទ្ធសាសនា។ ក្នុងន័យនេះ ការភ្ជួររាស់ គឺជាវិធីដើម្បីបង្កើតសណ្តាប់ធ្នាប់ថ្មី គឺជាការផ្តើមប្រតិបត្តិព្រះពុទ្ធសាសនា។ ចំណែកគម្ពីរព្រះពុទ្ធសាសនាមួយផ្នែកទៀត ក៏បានបង្ហាញពីសារសំខាន់នៃពិធីច្រត់ព្រះនង្គ័លដែរ គឺព្រះសិទ្ធថ ( ព្រះពុទ្ធ ) ត្រូវបិតាព្រះអង្គពរនឹងដៃចូលរួមពិធីច្រត់ព្រះនង្គ័ល។

នៅស្រុកឥណ្ឌា ភស្តុតាងទាក់ទងនឹងការភ្ជួររាស់លេចឡើងក្នុងទេវកថាដ៏ពេញនិយមមួយឈ្មោះថារាមកេរ្តិ៍ គឺជាពេលដែលព្រះជនក បានរកឃើញព្រះនាងសេតា ដែលជាបុត្រីរបស់ព្រះនាងធរណី ក្នុងវេលាដែលព្រះអង្គប្រារព្ធពិធីច្រត់ព្រះនង្គ័ល ដើម្បីធ្វើកិច្ចបូជាភ្ញើងដល់ព្រះនាងធរណី។[១០] ចំណែកទេវកថាដ៏ពេញនិយមមួយទៀតរបស់ស្រុកឥណ្ឌា ហើយដែលខ្មែរជ្រួតជ្រាបខ្លាំងដូចរឿងរាមកេរ្តិ៍ដែរនោះ គឺរឿងមហាភារត។ នៅក្នុងរឿងមហាភារត មានតួអង្គមួយឈ្មោះថា ពលរាម ដែលជាបងប្រុសរបស់ព្រះក្រិស្នៈ ( ព្រះវិស្ណុ )។ គាត់បានប្រើប្រាស់នង្គ័ល ដើម្បីកាយផ្លូវទឹកបង្កើតបានជាទន្លេយ៉ាមូណា និងរៀបចំដីថ្មីដែលបានទទួលពីការបែងចែករវាងបងប្អូន ដើម្បីបង្កបង្កើនផល។[១១] ត្រង់ចំណុចនេះ នៅក្នុងឯកសារខ្មែរបញ្ជាក់ថា ព្រះពលរាម ឬពលទេព ត្រូវបានព្រះក្រិស្នៈប្រសិទ្ធពរឱ្យជាធំក្នុងពូជធញ្ញាអាហារ ក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័ល។ គួរបញ្ជាក់ថាខ្មែរជាន់ដើមបានស្គាល់ព្រះពលរាមច្បាស់លាស់ណាស់ ពីព្រោះមានចម្លាក់ទោល និងក្រឡោតទាបមួយចំនួនបានបង្ហាញរូបព្រះអង្គ កាន់នង្គ័លដែលជាកេតនភណ្ឌ ( រូបលេខ២ )។[១២]

សរុបមក ព្រះរាជពិធីច្រត់ព្រះនង្គ័លជាកិច្ចពិធីមួយរបស់ព្រះមហាក្សត្រសម្រាប់ប្រកាសអនុញ្ញាតឱ្យជារាស្ត្រផ្តើមបង្កបង្កើនផលនៅលើដីដ៏បរិសុទ្ធ ដែលបានស្នើសុំជាកម្មសិទ្ធរបស់ព្រះមហាក្សត្រ ក្រោយពីពេលដែលព្រះអង្គបានធ្វើកិច្ចបូជាចំពោះព្រះធរណី

---

[៩] Ibit, 157.

[១០] Ibit, 157.

[១១] Ibit, 157.

[១២] ពុទ្ធសាសនបណ្ឌិត្យ, ១៩៤១:៩៣

និងទេពនិករទាក់ទងនឹងកសិកម្មទាំងឡាយ ហើយនឹងជានាផ្តល់គោគផលដ៏បរិបូណ៌ដល់កសិកម្ម។



រូបលេខ១៖ កិច្ចច្រត់ព្រះនង្គ័ល (រូបភាព: Vayofm.com)



រូបលេខ២៖ ការផ្សងគោឧសភរាជ ឱ្យបរិភោគអាហារ៧មុខ (រូបភាព: rfa.org)

អត្ថបទដោយ៖ មាស សុភាព



រូបលេខ៣៖ គំនូរច្រត់ព្រះនង្គ័លរបស់ភូមា (រូបភាព: Jstor.org)



រូបលេខ៤៖ ព្រះពលរាម កាន់នង្គ័ល ក្នុងហោរជាងចម្លាក់បន្ទាយស្រី (រូបភាព:សារមន្ទីរជាតិ)

## ឯកសារយោង


Armstrong, E. A.

1943, ‘The Ritual of the Plough’. *Folklore* 54, no. 1: 250–57.

Armstrong, Edward A.

1943, ‘The Triple-Furrowed Field’. *The Classical Review* 57, no. 1: 3–5.

Sahasrabudhe, Chetan, and Anurag Kashyap.

2016, ‘Festivals, Rituals, and Urban Landscape in Eighteenth-Century Maharashtra’. *South Asian Studies* 32: 1–11. https://doi.org/10.1080/02666030.2016.1191810.

SAHOO, P. C.

2016, ‘SĪTĀYAJÑA, AN AID TO ANCIENT AGRICULTURAL ENTERPRISE’. *Bulletin of the Deccan College Research Institute* 76: 119–26.


អត្ថបទដោយ៖ មាស សុភាព